# ការផ្ទៀងផ្ទាត់ចុះឈ្មោះ និងប្រើប្រាស់ពហុកត្តាដោយ Duo

ការចុះឈ្មោះចូល
ការផ្ទៀងផ្ទាត់
ឧបករណ៍ដាក់លាក់
គ្រប់គ្រងឧបករណ៍

# ការផ្ទៀងផ្ទាត់ពហុកត្តា

UMass បានជ្រើស Duo ជាអ្នកលក់សេវាកម្មផ្ទៀងផ្ទាត់ពហុកត្តា ហើយនិងកំពុងអនុវត្តវានៅលើសេវាកម្ម IT ដើម្បីបង្កើនសុវត្ថិភាព។

សម្រាប់ទិដ្ឋភាពទូទៅនៃសេវាកម្មផ្ទៀងផ្ទាត់ពហុកត្តា សូមមើល: [www.umass.edu/it/authentication](www.umass.edu/it/authentication)

សម្រាប់ទិដ្ឋភាពទូទៅនៃផលិតផល Duo សូមមើល: [guide.duo.com/](guide.duo.com/)

---

### យន្តរុករកដែលគាំទ្រ:

Chrome, Firefox, Safari, Internet Explorer 8 ឬថ្មីៗជាងនេះ, និង Opera

---

## ចុះឈ្មោះក្នុង Duo

Duo នាំលោក-អ្នកទៅកត្តាទីពីរ នៅពេលដែលអ្នកផ្ទៀងផ្ទាត់ក្នុងសេវាកម្មដែលដំណើរការដោយ Duo។ ជំហានបន្ទាប់ទៅទៀត រៀបរាប់លំអិតពីដំណើរការចុះឈ្មោះឧបករណ៍ណាមួយ ( ទូរស័ព្ទ, ថាបប្លេត, ឬទូរស័ព្ទខ្សែដីគោក ) ដើម្បីបម្រើជាកត្តាទី 2។

| |
|---|
| **ជំហានទី 1:**<br>ដំណើរទៅ [https://multifactor.umass.edu](https://multifactor.umass.edu) |
| **ជំហានទី 2:**<br>ស៊ីញ៉េចូលដោយអត្តសញ្ញាណផ្ទាល់របស់អ្នក( NetID ) និងពាក្យសម្ងាត់។ |
| **ជំហានទី 3:**<br>អ្នកគួរត្រូវបានគេប្តូរទិសទៅទំព័រមួយដែលមានចំណងជើងថា "ការគ្រប់គ្រងគណនីពហុកត្តា។" ចុច "បន្ត" ដើម្បីចាប់ផ្តើមដំណើរការនៃការចុះឈ្មោះឧបករណ៍ជាមួយ Duo។ |

**ជំហានទី 4:**

នៅត្រង់ទំព័រ "ការពារគណនីសាកលវិទ្យាល័យរដ្ឋម៉ាស្សាជូសេត្ស៍ អេមហឺស របស់អ្នក,"  ចុច "ចាប់ផ្តើម"។

**ជំហានទី 5:**

ជ្រើសប្រភេទនៃឧបករណ៍ដែលអ្នកចង់ប្រើជាមួយ Duo ហើយចុច "បន្ត"។

**ជំហានទី 5a:**

**សំរាប់ទូរស័ព្ទដៃ:**

1. បញ្ចូលលេខទូរស័ព្ទរបស់អ្នក។
2. គូសប្រអប់ដែលគេឱ្យគូសដើម្បីបញ្ជាក់លេខទូរស័ព្ទរបស់ឧបករណ៍អ្នក ហើយចុច "បន្ត"។
3. ចុចប្រភេទនៃទូរស័ព្ទដែលអ្នកកំពុងចុះឈ្មោះ (iPhone, Android, Windows Phone, ដទៃទៀត), ហើយចុច "បន្ត"។
4. តំឡើងកម្មវិធី Duo Mobile សម្រាប់ប្រភេទនៃឧបករណ៍ដែលអ្នកកំពុងចុះឈ្មោះ, ចូរមើលផ្នែកឧបករណ៍ដាក់លាក់ ឬធ្វើតាមសេចក្តីណែនាំនៅលើអេក្រង់។
5. ដំណើរការទៅ**ជំហានទី 6.**

**ជំហានទី 5b:**

**សំរាប់ថាបប្លេត:**

1. ជ្រើសរើសប្រភេទថាបប្លេតដែលអ្នកកំពុងដាក់បញ្ចូល (Android ឬ iOS) ហើយចុច "បន្ត"។
2. តំឡើងកម្មវិធី Duo Mobile សម្រាប់ប្រភេទនៃឧបករណ៍ដែលអ្នកកំពុងចុះឈ្មោះ, ចូរមើលផ្នែកឧបករណ៍ដាក់លាក់ ឬធ្វើតាមសេចក្តីណែនាំនៅលើអេក្រង់។
3. ដំណើរការទៅ**ជំហានទី 6.**

**ជំហានទី 5c:**

**សំរាប់ទូរស័ព្ទខ្សែជីគោក:**

1. បញ្ចូលលេខទូរស័ព្ទផ្លូវគោក (លេខពេញដោយមានទាំងលេខកូដតំបន់).
2. គូសប្រអប់ដែលគេឱ្យគូសដើម្បីបញ្ជាក់លេខទូរស័ព្ទដែលអ្នកទើបបញ្ចូល
3. ចុច "បន្ត"។
4. ដំណើរការទៅ**ជំហានទី 8.**

**ជំហានទី 6:**

បន្ទាប់ពីអ្នកបានដំឡើងកម្មវិធី(អាព) ត្រឡប់ទៅប្រអប់ចុះឈ្មោះនៅលើអេក្រង់កុំព្យូទ័ររបស់អ្នក ហើយចុច "ខ្ញុំមាន Duo Mobile"។

**ជំហានទី7a:**

**បើកប្រើ Duo Mobile ដោយប្រើលេខកូដ QR:**

សម្រាប់ទូរស័ព្ទ iPhone, Android និង Windows Phone បើកប្រើ Duo Mobile ដោយស្រាវយក(ស្កេន) លេខកូដ QR ដោយប្រើម៉ាស៊ីនស្កេនភ្ជាប់មកជាមួយក្នុងអាពរបស់ Duo Mobile:

1. បើក Duo Mobile អាពក្នុងឧបករណ៍របស់អ្នក។
2. ក្នុងអាព Duo Mobile, ចុចសញ្ញា "+"។
3. ចាប់យកកូដ QR ដែលបង្ហាញនៅលើប្រអប់ "បើកប្រើ Duo Mobile" នៅលើអេក្រង់កុំព្យូទ័ររបស់អ្នកជាមួយឧបករណ៍របស់អ្នក។
4. នៅពេលដែលអ្នកចាប់យកកូដ QR ប៊ូតុង "បន្ត" នៅលើប្រអប់ "បើកប្រើ Duo Mobile" នៅលើអេក្រង់កុំព្យូទ័ររបស់អ្នកគួរត្រូវបានបំភ្លឺពណ៌។
5. ចុច "បន្ត"។
6. គណនីសាកលវិទ្យាល័យរដ្ឋម៉ាស្សាជូសេត្ស៍ អេមហឺស របស់អ្នកឥឡូវគួរចុះក្នុងបញ្ជីអាព Duo Mobile។
7. ដំណើរការទៅ**ជំហានទី 8.**

**ជំហានទី 7b:**

**បើកប្រើ Duo Mobile តាមរយៈអ៊ីម៉ែល:**

បើអ្នកមិនអាចចាប់យកកូដ QR បានទេ អ្នកអាចចាប់ប្រើ Duo Mobile អាពតាមរយៈអ៊ីម៉ែលរបស់អ្នក។

1. ចុច "ឬ, ឱ្យគេផ្ញើទំព័រសំរាប់ផ្តើមប្រើទៅអ៊ីម៉ែលរបស់អ្នកវិញក៏បានដែរ"។
2. ផ្តល់អាស័យដ្ឋានអ៊ីម៉ែលដែលអ្នកអាចប្រើក្នុងឧបករណ៍របស់អ្នកបាន។
3. ចុច "ផ្ញើអ៊ីម៉ែល"។
4. ចូលទៅក្នុងអ៊ីម៉ែល UMass របស់អ្នក ហើយរកមើលអ៊ីម៉ែលដែលគេផ្ញើទៅអ្នកពីសន្តិសុខ Duo។ (**សំគាល់:** អ្នកនឹងត្រូវការអនុវត្តជំហានដូចតទៅនៅលើឧបករណ៍ដែលអ្នកព្យាយាមចុះឈ្មោះ និងដែលអ្នកទើបតែបានបញ្ចូលអាព Duo Mobile ក្នុងនោះ។)
5. ចុចចំណុចបន្តក្នុងអ៊ីម៉ែលនៅក្នុងឧបករណ៍របស់អ្នក។
6. ចុច "បើក " ដើម្បីបើកទំព័រនៅក្នុង Duo Mobile។ **សំគាល់:** ជំហាននេះអាចប្លែកអាស្រ័យទៅលើឧបករណ៍ដែលអ្នកកំពុងប្រើប្រាស់។
7. អាព Duo Mobile គួរតែបើកជាស្វ័យប្រវត្តិ អ៊ីម៉ែល UMass របស់អ្នកឥឡូវគួរតែមានចុះក្នុងបញ្ជីក្នុងអាព Duo Mobile។
8. ត្រឡប់ទៅប្រអប់ "បើកប្រើ Duo Mobile ដោយអ៊ីម៉ែល" ក្នុងអេក្រង់កំព្យូទ័ររបស់អ្នក ហើយប៊ូតុង "បន្តទៅទៀត" គួរតែក្លាយជាព៌ណបៃតង។
9. ចុច "បន្ត"។
10. ដំណើរការទៅ**ជំហានទី 8.**

**ជំហានទី 8:**

អ្នកគួរតែត្រូវគេបង្វែទៅទំព័រមានចំណងជើងថា "ការកំណត់ និងឧបករណ៍របស់ខ្ញុំ"។ ក្នុងទំព័រនេះ អ្នកអាច:

- ប្តូរឈ្មោះឧបករណ៍នៅខាងក្រោម "ជម្រើសឧបករណ៍"។
- ផ្តើមប្រើប្រាស់ Duo Mobile វិញ បើសិនអ្នកលុបគណនីរបស់អ្នកពីអាព Duo Mobile ខាងក្រោម "ជម្រើសឧបករណ៍"។
- ប្តូរឧបករណ៍ដែលអ្នកប្រាថ្នាចង់បើកហើយប្រើដើម្បីផ្ទៀងផ្ទាត់មើល។
- កំណត់វិធីសាស្រ្តផ្ទៀងផ្ទាត់ស្វ័យប្រវត្តិ

ត្រូវប្រាកដថាចុច "រក្សាទុក" បើអ្នកធ្វើការផ្លាស់ប្តូរ។
នៅពេលអ្នកបញ្ចប់ការកែសម្រួលការកំណត់ សូមចុច "បន្តទៅស៊ីញ៉េចូល"។
អ្នកគួរតែឃើញសារដូចខាងក្រោម: "ការចុះឈ្មោះទទួលបានជោគជ័យ!"

**ជំហានទី 9:**

ឥឡូវអ្នកត្រូវបានបង្កើតឡើងដើម្បីផ្ទៀងផ្ទាត់ជាមួយ Duo លើឧបករណ៍ចល័តរបស់អ្នកទៅសេវាកម្ម UMass Amherst ដោយប្រើវិធីសាស្ត្រផ្ទៀងផ្ទាត់ដូចខាងក្រោម:

- ការជូនដំណឹងដោយ Push
- ការទូរស័ព្ទហៅ
- លេខសម្ងាត់

សូមមើលផ្នែកខាងក្រោមសម្រាប់ការណែនាំអំពីរបៀបផ្ទៀងផ្ទាត់ទៅសេវាកម្មផ្តល់ដោយ Duo នៅ UMass Amherst ដែលបានបើកជាមួយ Duo។

# ផ្ទៀងផ្ទាត់ជាមួយ Duo

**ជំហានទី 1:**

បើកយន្តរុករកអ៊ីនធ័រណេត ហើយឆ្លងកាត់ទៅរកសេវាដែលអ្នកចង់ចូលប្រើ។

**ជំហានទី 2:**

បញ្ចូល NetID និងពាក្យសម្ងាត់របស់អ្នកទៅក្នុងច្រកសមរម្យ ហើយចុច "ស៊ីញ៉េចូល"។

**ជំហានទី 3:**

អ្នកគួរត្រូវបានប្តូរទិសទៅប្រអប់ស្វ័យប្រវត្តិដែលនឹងអនុញ្ញាតឱ្យអ្នកជ្រើសរើសវិធីដែលអ្នកចង់ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក។ នេះត្រូវបានហៅថា**ប្រអប់ស្វ័យប្រវត្តិផ្ទៀងផ្ទាត់** Duo:




**ជំហានទី 4:**

ជ្រើសឧបករណ៍ដែលអ្នកចង់ផ្ទៀងផ្ទាត់ជាមួយ។

**សំគាល់:** ប្រសិនបើលោក-អ្នកមានឧបករណ៍ច្រើនជាងមួយដែលបានចុះឈ្មោះនៅក្នុង Duo វានឹងមានម៉ឺនុយទម្លាក់ចុះបង្ហាញសម្រាប់អ្នកដើម្បីជ្រើសរើសឧបករណ៍ណាដែលអ្នកចង់ផ្ទៀងផ្ទាត់។

| |
|---|
| **ជំហានទី 5:**<br>លោក-អ្នកនឹងត្រូវបានដាស់តឿនឱ្យ "ជ្រើសរើសមធ្យោបាយផ្ទៀងផ្ទាត់" ពីចំណុចខាងក្រោម:<br>• Duo Push<br>• ទូរស័ព្ទមកខ្ញុំ<br>• ពាក្យសម្ងាត់ |
| **ជំហានទី 5a:**<br><br>**Duo Push តាមរយៈឧបករណ៍ចល័ត**<br><br>ជ្រើស "ផ្ញើ Push មកខ្ញុំ"<br><br>អ្នកនឹងទទួលសំណើស៊ីញ៉េចូលរបស់ Duo Mobile ជាមួយឈ្មោះសេវាកម្មដែលអ្នកកំពុងព្យាយាមចូលប្រើលើឧបករណ៍ចល័តដែលអ្នកបានចុះឈ្មោះក្នុង Duo។<br><br>នៅលើឧបករណ៍ចល័តរបស់អ្នក សូមជ្រើសរើសការជូនដំណឹង ហើយអ្នកនឹងត្រូវបានជម្រុញឱ្យយល់ព្រម ឬបដិសេធសំណើ។ អ្នកអាចបញ្ចប់ជំហាននេះតាមរយៈការជូនដំណឹងនៅលើអេក្រង់ចាក់សោរបស់អ្នក ឬនៅក្នុងកម្មវិធី Duo Mobile:<br><br>1. ជ្រើស "យល់ព្រម" ដើម្បីផ្ទៀងផ្ទាត់ពីអេក្រង់ចាក់សោឧបករណ៍របស់អ្នក។<br>**ឬ**<br>2. បើកកម្មវិធី Duo Mobile លើឧបករណ៍ដែលអ្នកបានចុះឈ្មោះ។<br>3. ចុចលើ "សំណើកំពុងរង់ចាំ 1។ ចុចដើម្បីឆ្លើយតប ... " អក្សរនោះ។<br>4. ចុច "យល់ព្រម។"<br>5. បន្ទាប់ពីនោះ ត្រឡប់ទៅយន្តរុករកដែលអ្នកបានបើកនៅជំហានទីមួយ, ហើយអ្នកគួរតែត្រូវបានស៊ីញ៉េចូលក្នុងសេវាកម្មហើយ។<br><br>ប្រសិនបើអ្នកទទួលបានសំណើស៊ីញ៉េចូលប្រព័ន្ធ Duo Mobile ដែលអ្នកមិនទាន់បានចាប់ផ្តើមផង ចូរជ្រើស "បដិសេធ"។ ប្រសិនបើអ្នកនៅក្នុងកម្មវិធី Duo ចល័ត អ្នកអាចជ្រើសរើសហេតុផលនៃការបដិសេធសំណើនោះ។ |
| **ជំហានទី 5b:**<br><br>**ទូរស័ព្ទមកខ្ញុំតាមរយៈឧបករណ៍ចល័ត ឬខ្សែដីគោក**<br><br>1. ជ្រើស "ទូរស័ព្ទមកខ្ញុំ"។<br>2. អ្នកនឹងទទួលការទូរស័ព្ទហៅក្នុងឧបករណ៍ដែលបានចុះឈ្មោះក្នុង Duo ។<br>3. អ្នកនឹងឮសារស្វ័យប្រវត្តិដែលនិយាយថា "ស្វាគមន៍មកកាន់ Duo។ ប្រសិនបើអ្នកមិនរំពឹងការទូរព័ព្ទហៅនេះទេ សូមព្យួរទូរស័ព្ទ។ បើមិនដូច្នោះទេ សូមចុចប៊ូតុងណាមួយដើម្បីស៊ីញ៉េចូល។ "<br>4. ចុចប៊ូតុងណាមួយក៏ដោយនៅលើឧបករណ៍ចល័តរបស់អ្នក។ |

5. រួចហើយ ត្រឡប់ទៅយន្តរុករកបណ្ដាញដែលអ្នកបានបើកក្នុងជំហានទីមួយ ហើយអ្នកគួរតែត្រូវបានស៊ីញ៉េចូលក្នុងសេវាកម្មហើយ។

បើអ្នកព្យួរទូរស័ព្ទដោយមិនបានចុចប៊ូតុងណាមួយនៅក្នុងទូរស័ព្ទរបស់អ្នកទេ ការស្នើស៊ីញ៉េចូលនឹងត្រូវបដិសេធ។

**ជំហានទី 5c:**

**កូដសម្ងាត់ Duo តាមកម្មវិធីក្នុងឧបករណ៍ចល័ត**

1. ជ្រើស "បញ្ចូលកូដសម្ងាត់"។
2. ទៅកម្មវិធី Duo ក្នុងឧបករណ៍ចល័តរបស់អ្នក។
3. ចុចរូបប៊ូតុងបៃតងនៅជិតឈ្មោះសេវាកម្ម។
4. ត្រឡប់ទៅយន្តរុករកបណ្ដាញ និងបញ្ចូលលេខសម្ងាត់ពេលជំរុញឱ្យផ្ទៀងផ្ទាត់។
5. ឥឡូវ អ្នកគួរតែត្រូវបានស៊ីញ៉េចូលក្នុងសេវាកម្មហើយ។

**សំគាល់:** កូដសម្ងាត់អាចត្រូវប្រើដើម្បីផ្ទៀងផ្ទាត់សេវាកម្មបានដែរ បើទោះណាអ្នកមិនមានអ៊ីនធ័រណេត។

## ឧបករណ៍ជាក់លាក់

### Android

អ្នកអាចទទួលបានកម្មវិធី Duo Mobile ពី Google Play:
https://play.google.com/store/apps/details?id=com.duosecurity.duomobile&hl=en

វគ្គបច្ចុប្បន្ននៃ Duo Mobile គាំទ្រប្រព័ន្ធប្រតិបត្តិការ Android 4.0 និងខ្ពស់ជាងនេះ។

សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើ Duo ជាមួយឧបករណ៍ Android របស់អ្នក ចុចទីនេះ
https://guide.duo.com/android

### iOS

អ្នកអាចទទួលបានកម្មវិធី Duo Mobile ពីហាង App:
https://itunes.apple.com/us/app/duo-mobile/id422663827?mt=8

វគ្គបច្ចុប្បន្ននៃ Duo Mobile គាំទ្រប្រព័ន្ធប្រតិបត្តិការ iOS 7 និងខ្ពស់ជាងនេះ។

សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើ Duo ជាមួយឧបករណ៍ iPhone របស់អ្នក ចុចទីនេះ:
https://guide.duo.com/iphone

### ទូរស័ព្ទ Windows

អ្នកអាចទទួលបានកម្មវិធី Duo Mobile ពីហាង Microsoft:
https://www.microsoft.com/en-us/store/p/duo-mobile/9nblggh08m1g

វគ្គបច្ចុប្បន្ននៃ Duo គាំទ្រ Windows Phone 8 និងខ្ពស់ជាងនេះ។ មើលឯកសារកម្មវិធីចាស់ៗ សម្រាប់ទូរស័ព្ទ Windows 7: https://guide.duo.com/windows7-phone

សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើ Duo ជាមួយឧបករណ៍ Windows phone របស់អ្នក ចុចទីនេះ: https://guide.duo.com/windows-phone

### ខ្សែដីគោក

ប្រសិនបើអ្នកមិនអាចទាញយកកម្មវិធី Duo Mobile ឬចង់ផ្ទៀងផ្ទាត់តាមរយៈខ្សែដីគោកណាមួយ អ្នកអាចទទួលការទូរស័ព្ទហៅ:

- នៅប្រអប់បញ្ចូលការផ្ទៀងផ្ទាត់ ពីម៉ឺនុយទម្លាក់ចុះក្នុង "ឧបករណ៍" ជ្រើស ឬបញ្ជាក់ឧបករណ៍ដែលអ្នកចង់ទទួលទូរស័ព្ទហៅចូលពី។
- ចុចប៊ូតុង "ទូរស័ព្ទមកខ្ញុំ" ហើយ Duo នឹងទូរស័ព្ទមកអ្នក។
- អ្នកអាចចុចប៊ូតុងណាមួយនៅលើទូរស័ព្ទរបស់អ្នកបន្ទាប់ពីស្តាប់ការជំរុញ ដើម្បីស៊ីញ៉េចូលក្នុងសេវាកម្មនៅលើយន្តរុករកអ៊ីនធឺណេត។

### សារអត្ថបទតាមរយៈលេខសម្ងាត់:

- អ្នកក៏អាចទទួលបានសារអត្ថបទពី Duo ដោយជ្រើសរើសឧបករណ៍ដែលអ្នកចង់ទទួលបានអត្ថបទនោះ (នេះគួរតែជាឧបករណ៍ដែលបានចុះឈ្មោះជាមួយ Duo)។
- លើយន្តរុករកអ៊ីនធឺណិត នៅប្រអប់បញ្ចូលការផ្ទៀងផ្ទាត់ ជ្រើសឧបករណ៍ដែលអ្នកចង់ទទួលសារនោះ។
- ជ្រើស "បញ្ចូលកូដសម្ងាត់"។
- ប្រអប់ពណ៌ខៀវមួយគួរតែលេចឡើងដែលនិយាយថា "បញ្ចូលលេខកូដសម្ងាត់ពី Duo ចល័ត ឬសារ។" ហើយចុច "ផ្ញើលេខកូដថ្មីមកខ្ញុំ" ។
- នៅលើទូរស័ព្ទរបស់អ្នក អ្នកគួរទទួលបានសារដែលមានលេខកូដសម្ងាត់ពីរបី។
- លើយន្តរុករកអ៊ីនធឺណេត នៅខាងលើប៊ូតុង"ស៊ីញ៉េចូល" បញ្ចូលលេខសម្ងាត់មួយ ហើយចុច"ស៊ីញ៉េចូល"
- អ្នកគួរតែត្រូវបានស៊ីញ៉េចូលក្នុងសេវាកម្មហើយ។

សម្រាប់ព័ត៌មានបន្ថែមក្នុងការប្រើទូរស័ព្ទដៃ ឬក៏ខ្សែដីគោកជាមួយ Duo, ចុចទីនេះ: https://guide.duo.com/other-phones

## ចាត់ចែងឧបករណ៍នានា

បើសិនជាអ្នកចង់ផ្លាស់ប្តូរជម្រើសសម្រាប់ឧបករណ៍នានាដែលអ្នកបានចុះឈ្មោះក្នុង Duo អ្នកអាចធ្វើ:

- ទៅ https://multifactor.umass.edu
- ស៊ីញ៉េចូលដោយប្រើ NetID និងពាក្យសម្ងាត់របស់អ្នក។
- ចុច "បន្តទៅមុខ"។
- ចុចលើ "**ការកំណត់និងឧបករណ៍របស់ខ្ញុំ** "។

ផ្ទៀងផ្ទាត់តាមរយៈ Duo ដោយជ្រើសរើសឧបករណ៍ផ្ទៀងផ្ទាត់ ហើយបន្ទាប់មក វិធីសាស្ត្រផ្ទៀងផ្ទាត់។ (សូមមើលការផ្ទៀងផ្ទាត់)។

បន្ទាប់ពីអ្នកផ្ទៀងផ្ទាត់
ឥឡូវអ្នកអាចផ្លាស់ប្តូរនូវជំរើសជាច្រើនសម្រាប់ឧបករណ៍ណាមួយដែលអ្នកបានចុះឈ្មោះជាមួយ Duo។ អ្នកអាច:

- ធ្វើឱ្យសកម្មឡើងវិញនូវ Duo Mobile បើសិនជាអ្នកលុបគណនីសាកលវិទ្យាល័យ Massachusetts Amherst របស់អ្នកចេញពីកម្មវិធី Duo Mobile។
- ប្តូរឈ្មោះឧបករណ៍។
- លុបឧបករណ៍ចោល។
- បន្ថែមឧបករណ៍មួយទៀត។
- ជ្រើសឧបករណ៍ប្រចាំការដែល Duo នឹងជ្រើសរើសសម្រាប់ការផ្ទៀងផ្ទាត់។
- ជ្រើសរើសវិធីសាស្ត្រផ្ទៀងផ្ទាត់ដែលអ្នកចូលចិត្ត។

ត្រូវប្រាកដថារក្សានូវការផ្លាស់ប្តូរណាមួយដែលអ្នកធ្វើដោយចុចលើប៊ូតុង "រក្សាទុក"។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការគ្រប់គ្រងឧបករណ៍ជាមួយ Duo ចុចទីនេះ: https://guide.duo.com/manage-devices